Tips / know How

ផ្លាស់ប្តូរចំណេះដឹង

Knowledge

ដោយ : ធារ៉ា

ONLINE Expand Your World

# ទូរស័ព្ទហៅចេញទៅក្រៅប្រទេស ពីកុំព្យូទ័រទៅកាន់ទូរស័ព្ទតាមរយៈកាត 3Tel

បច្ចុប្បន្ន មធ្យោបាយទំនាក់ទំនងទូរស័ព្ទហៅចេញទៅក្រៅប្រទេសនៅក្នុងស្រុកយើង ភាគច្រើនត្រូវបានគេជ្រើសរើស និងបង្វែរមកប្រើប្រាស់តាមប្រព័ន្ធទូរស័ព្ទហៅចេញពីកុំព្យូទ័រទៅកាន់ទូរស័ព្ទ (PC-to-Phone) វិញម្តង។ មូលហេតុដោយសារតែ លក្ខណៈងាយស្រួល និងអាត្រាតម្លៃក្នុងការហៅចេញមានកំរិតដ៏ទាបបំផុត ទើបធ្វើឱ្យសេវាកម្មនេះមានភាពពេញនិយមយ៉ាងខ្លាំងនាពេលសព្វថ្ងៃ។ ក្នុងនោះក្រុមហ៊ុន Online ដែលជាក្រុមហ៊ុនបំរើសេវាកម្មផ្នែកអ៊ិនធើណែតដ៏ធំមួយនៅក្នុងព្រះរាជាណាចក្រកម្ពុជា ក៏បានផ្តល់នូវសេវាកម្មថ្មីនេះដល់អតិថិជនរបស់ខ្លួនគ្រប់ស្រទាប់ផងដែរ។ សេវាកម្មថ្មីរបស់ក្រុមហ៊ុន Online មួយនេះ ដើរលើប្រព័ន្ធ 3tel ដែលតំរូវឱ្យលោកអ្នកមានកុំព្យូទ័រ1 គ្រឿង បំពាក់ដោយប្រព័ន្ធអ៊ិនធើណែត ឧបករណ៍មីក្រូហ្វូន និងឧបករណ៍បំពងសម្លេង រួចប្រើកាត 3tel (Prepaid Calling Card) ពីក្រុមហ៊ុន Online ដើម្បីអាចមានលទ្ធភាពទូរស័ព្ទហៅចេញទៅក្រៅប្រទេសតាមរយៈកុំព្យូទ័រទៅកាន់ទូរស័ព្ទបាន។

ដើម្បីប្រើសេវាកម្មនេះបាន លោកអ្នកគ្រាន់តែធ្វើតាមតំរូវការមួយចំនួនដូចខាងក្រោមប៉ុណ្ណោះ:

**តំរូវការប្រើប្រាស់**

1. កុំព្យូទ័រភីស៊ី ឬយួរដៃ (Laptop) បំពាក់ដោយប្រព័ន្ធអ៊ិនធើណែត
2. កាសស្តាប់ត្រចៀកដែលមានមីក្រូហ្វូនស្រាប់ (Headphone)
3. កាតហៅចេញទៅក្រៅប្រទេស (PC to Phone) របស់ក្រុមហ៊ុន Online (Prepaid Calling Card) ដែលមានតម្លៃចាប់ពី 5ដុល្លា , 10ដុល្លា និង 20ដុល្លា ដែលលោកអ្នកអាចរកជាវបាននៅក្រុមហ៊ុន Online
4. កម្មវិធី X-Lite សំរាប់ប្រើទូរស័ព្ទហៅចេញទៅក្រៅប្រទេស ដែលអាចដោនឡូដពីវិបសាយ www.3tel.com.kh




## របៀបដំឡើងកម្មវិធីទូរស័ព្ទហៅចេញទៅក្រៅប្រទេសពីកុំព្យូទ័រទៅកាន់ទូរស័ព្ទ

ជំហានដំបូង លោកអ្នកត្រូវមានកុំព្យូទ័រ 1 គ្រឿង ដែលមានភ្ជាប់ប្រព័ន្ធអ៊ិនធើណែត និងមានបំពាក់ដោយឧបករណ៍ HeadPhone (កាសស្តាប់ត្រចៀក ដែលមានមីក្រូហ្វូន) រួចជាស្រេច។ ដូច្នេះ លោកអ្នកគ្រាន់តែត្រូវការដំឡើងកម្មវិធី X-Lite ប៉ុណ្ណោះ តាមរយៈការដោនឡូដពីវិបសាយ www.3tel.com.kh ដើម្បីមកធ្វើការដំឡើងនៅក្នុងម៉ាស៊ីនកុំព្យូទ័ររបស់លោកអ្នក។

**របៀបអនុវត្តន៍**

1. ជំហានដំបូង សូមបើកវិបសាយ www.3tel.com.kh រួចចុចលើរូបភាព Download Free SIP Soft Phone ដើម្បីធ្វើការដោនឡូដកម្មវិធី X-Lite ។






**2.** បន្ទាប់មកទៀត ចុចប៊ូតុង Save ដើម្បីរក្សាទុកកម្មវិធីនេះ នៅក្នុងម៉ាស៊ីនរបស់លោកអ្នក




**3.** រួចដំណើរការកម្មវិធីដែលលោកអ្នកបានដោនឡូដរួច បន្ទាប់មកចុចប៊ូតុង Run ដើម្បីដំណើរការដំឡើងកម្មវិធី ។




**4.** ដំហានបន្ទាប់ទៀតចុចលើប៊ូតុង Next រួចធ្វើតាមការណែនាំរបស់អេក្រង់កម្មវិធីរហូតដល់ចប់ជាការស្រេច ។

## របៀបប្រើប្រាស់



ក្រោយពេលលោកអ្នកដំឡើងកម្មវិធីរួចរាល់ហើយ វានឹងបង្ហាញរូបភាព Icons នៃកម្មវិធីនេះនៅលើ Desktop ។ ដូច្នេះ លោកអ្នកគ្រាន់តែចុចពីរដងលើ Icons: X-Lite នោះលោកអ្នកនឹងអាចប្រើកម្មវិធីនេះ ដើម្បីដំណើរការទូរស័ព្ទ ហៅចេញទៅក្រៅប្រទេសបាន ។

មុននឹងលោកអ្នកអាចហៅចេញទៅក្រៅបាន លោកអ្នកត្រូវបំពេញបែបបទមួយចំនួននៅក្នុងកម្មវិធី X-Lite ដូចខាងក្រោម:

**1.** ដំហានដំបូងលោកអ្នកត្រូវចូលទៅ Show Menu រួចជ្រើសរើសយក SIP Account Settings សូមមើលរូបខាងក្រោម:




**2.** នៅពេលលោកអ្នកជ្រើសរើស SIP Account Settings វានឹងបង្ហាញ SIP Account ដូចរូបខាងក្រោម ។ បន្ទាប់មកចុចលើប៊ូតុង Add




**3.** រួចបំពេញឈ្មោះ លេខគណនី និងលេខ Pin code ដែលលោកអ្នកបានមកពីការជាវកាត 3tel របស់ក្រុមហ៊ុន Online ។ រួចចុចប៊ូតុង OK




**4.** នៅពេលលោកអ្នកបំពេញឈ្មោះ លេខគណនី និង បញ្ចូលលេខ PIN Code ត្រឹមត្រូវរួចរាល់ហើយ នោះលោកអ្នកអាចប្រើប្រាស់សេវាកម្មនេះបាន ។ លោកអ្នកគ្រាន់តែបំពេញលេខទូរស័ព្ទនៅក្រៅប្រទេស ដែលលោកអ្នកចង់ទូរស័ព្ទចេញ ទៅក្នុងប្រអប់វាយលេខ ដែលមានទំរង់ជាលេខកូដប្រទេស + លេខកូដតំបន់ + លេខទូរស័ព្ទ រួចចុចប៊ូតុងហៅចេញ (Call) ជាការស្រេច ។៕




**អត្រាតម្លៃហៅចេញទៅក្រៅប្រទេស**

| ប្រទេស | អត្រាតម្លៃ (USD/1 នាទី) |
|---|---|
| Singapore | = 0.05 |
| India | = 0.21 |
| USA | = 0.05 |
| China | = 0.05 |
| Thailand | = 0.08 |
| Malaysia | = 0.06 |
| Laos | = 0.58 |
| France | = 0.05 |
| Vietnam | = 0.29 |
| Australia | = 0.05 |